ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៧/១៨ - យែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦២ ៦៨ ៦៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក ហំ ភា មេធាវី

២- លោក ហុន វិនដា ជំនួយការមេធាវី

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៧ ៧៧ ៧៨ ១៩ ទូរសារ ៖ គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | ប្រធានកម្មវិធីដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោកស្រី ឃួន សុខា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យ៉ៃនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី |
| ៣- លោក ចាប ដា | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យ៉ៃនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី |
| ៤- លោក វុទ្ធី ឆាន្ទី | ដេរ |
| ៥- លោក ប៊ុត វន្ទី | ជាង |
| ៦- លោក អឿ ប៊ិន | ដេរ |
| ៧- លោកស្រី សាន់ ណង់ | ដេរ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនបន្ថែមប្រាក់ថ្លៃបាយថ្ងៃត្រង់ ចំនួន ១០ ដុល្លារ លើប្រាក់ថ្លៃបាយថ្ងៃត្រង់កំពុងមានស្រាប់ ចំនួន ៦ ដុល្លារ សរុបស្មើ ១៦ ដុល្លារ ក្នុង១ខែ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ជូនឡើយ ។

២- ភាគីកម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនបន្ថែមប្រាក់ថ្លៃបាយធ្វើការថែមម៉ោង ក្នុងមួយម៉ោង ២០០០ រៀល ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ជូនឡើយ ។

៣- ភាគីកម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់អតីតភាពការងារតាមឆ្នាំ (១២ឆ្នាំ ស្មើ ១២ ដុល្លារ ១៣ឆ្នាំ ស្មើ ១៣ ដុល្លារ) ។ ល ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់ ។

៤- ភាគីកម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការថែមម៉ោង មួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃសៅរ៍ ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចរៀបចំជូនបានទេ ដោយក្រុមហ៊ុននៅតែរក្សាគោលការណ៍ដដែល គឺបើកជូន ២ សប្តាហ៍ម្តង ព្រោះក្រុមហ៊ុនមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ

THE ARBITRATION COUNCIL

០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យែនធេរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី លេខ ១១៤ ក.ប/អក/វក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៩៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ០៥កើត ខែផល្គុន ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានីតិវិធីៈ**

នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ ការិយាល័យវិវាទការងារទី៤ បានទទួលពាក្យបណ្តឹងរបស់កម្មករ-និយោជិតនៃក្រុមហ៊ុន យែនធេរេន អ៊ីភែរីល (ខេមបូឌា) ទាមទារឱ្យនិយោជកកែលម្អលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយ និងផ្សះផ្សាវិវាទ ចំនួន ៥ ចំណុច នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ១ ចំណុច និងចំណុចមិនសះជា ចំនួន ៤ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ទាំង ៤ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យែនធេរេន អ៊ីភែរីល (ខេមបូឌា) លេខ ១១៤ ក.ប/អក/វក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ៤ ចំណុច នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ៤ ចំណុចនេះ បន្ថែមទៀត ដោយភាគីកម្មករនិយោជិត

បានសម្រេចដកចំណុចវិវាទទី១, ទី២ និងទី៣ ចេញពីការទាមទារក្នុងសំណុំរឿង។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាតែចំណុចវិវាទដែលនៅសល់ ចំនួន ១ ចំណុច តែប៉ុណ្ណោះ គឺចំណុចវិវាទទី៤។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) ប្រគល់សិទ្ធិជូនលោកមេធាវី ហំ ភា។

២- លិខិតជូនដំណឹង លេខ ១២២ គ្លរី/១៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ របស់មេធាវី ហំ ភា ជម្រាបជូន លោកប្រធានសហព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី លេខ លេខ ១១៤ ក.ប/អក/វក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី លេខ ០០៦/១៨ កប/អក/វក/លបវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៤៧ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ០៩ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៤៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ០៩ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា) តទៅនេះហៅថា "ក្រុមហ៊ុន យៃនធើរេន" គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់។ បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិត ចំនួនប្រហែលជា ១០៦០ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា))* ។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី ទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាសហជីព ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៣១០១ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ និងបានទទួលលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព ចំនួន ៣ នាក់ គឺ ១. ឃួន សុខា ជាប្រធាន ២. ចាប ដា ជាអនុប្រធាន និង ៣. ឆេង គីមស្រ៊ាន់ ជាលេខាធិការ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣។
- នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៦/១៨ កប/អក/វក/លបវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. ឃួន សុខា ២. ចាប ដា និង ៣. អ៊ិន ស្រី ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា) ដើម្បីដោះស្រាយវិវាទការងាររួមនៃសំណុំរឿងនេះ។
- នៅថ្ងៃសវនាការ មានវត្តមានកម្មករនិយោជិត ចំនួន ៦ នាក់ ដោយក្នុងនោះ មានកម្មករនិយោជិតចំនួន ២ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតខាងលើផងដែរ គឺកម្មករនិយោជិត ឃួន សុខា និង ចាប ដា។
- ភាគីនិយោជកបានជំទាស់នឹងសិទ្ធិតំណាងរបស់ភាគីកម្មករនិយោជិត តាមរយៈការលើកឡើងនៅក្នុងសវនាការថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី មិនបានបំពេញលក្ខខណ្ឌស្របតាមមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ដើម្បីអាចឱ្យសហជីពនេះ យកវិវាទការងាររួមមកដោះស្រាយជាមួយនឹងក្រុមហ៊ុនបានឡើយ។

- យោងតាមកំណត់ហេតុផ្សះផ្សាវិវាទការងាររួម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា កម្មករដែលពាក់ព័ន្ធនឹងវិវាទនេះ មានចំនួន ៣៨០ នាក់។

**ចំណុចវិវាទទី ៤ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្ដាហ៍ម្ដង រៀងរាល់ថ្ងៃសៅរ៍***

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតរៀងរាល់មួយសប្ដាហ៍ម្ដង គឺនៅថ្ងៃសៅរ៍នៃសប្ដាហ៍នីមួយៗ។
- ភាគីទាំងពីរទទួលស្គាល់ថា ជាការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន និយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ចំនួន ២ ដង ក្នុងមួយខែ (២សប្ដាហ៍ម្ដង) គឺនៅថ្ងៃទី៣ និងទី១៨ នៃខែនីមួយៗ។ ក្នុងករណី ថ្ងៃទី៣ ឬ ថ្ងៃទី១៨ នោះ ប៉ះចំថ្ងៃបុណ្យ ឬថ្ងៃអាទិត្យ និយោជកនឹងលើកថ្ងៃបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតទៅថ្ងៃធ្វើការបន្ទាប់។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ○ កម្មករនិយោជិតត្រូវការប្រាក់ដើម្បីទិញម្ហូបអាហារ និងសម្ភារៈប្រើប្រាស់ជារៀងរាល់ថ្ងៃ ហើយទំនិញនៅទីផ្សារក៏ឡើងថ្លៃ ហេតុនេះ ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២ សប្ដាហ៍ម្ដង បង្កការលំបាកដល់កម្មករនិយោជិត ដោយពួកគាត់ត្រូវខ្ចីប្រាក់គេ ឬត្រូវយកប្រាក់ពីផ្ទះមកចាយសិនទម្រាំដល់ថ្ងៃបើកប្រាក់។
  - ○ ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មិនមានការលំបាកក្នុងគណនានោះទេ។
  - ○ យោងតាមសេចក្ដីបង្គាប់អាជ្ញាកណ្ដាល មុនៗ បានសម្រេចថា និយោជកមានកាតព្វកិច្ចក្នុងការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ស្របតាមការទាមទាររបស់កម្មករនិយោជិត។
- ភាគីនិយោជកបានបញ្ជាក់ជំហរថា មិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ពីព្រោះ ៖
  - ○ ច្បាប់ស្ដីពីការងារមិនបានកំណត់ថា ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ត្រូវតែធ្វើឡើងនៅថ្ងៃណាមួយជាក់លាក់នោះទេ។
  - ○ ការទាមទាររបស់កម្មករនិយោជិតមិនសូវខុសគ្នាពីការអនុវត្តរបស់និយោជកនោះទេ ហើយបើទោះជានិយោជកបើកជូនកម្មករនិយោជិត ២ ដង ក្នុងមួយខែ ក៏ប្រាក់របស់កម្មករនិយោជិតមិនបាត់បង់នោះដែរ។
  - ○ និយោជកត្រូវការពេលវេលាច្រើនដើម្បីគណនា និងបើកប្រាក់ជូនកម្មករនិយោជិត។

## ហេតុផលនៃសេចក្ដីសម្រេច ÷

នៅក្នុងករណីនេះ ភាគីនិយោជកបានជំទាស់នឹងសិទ្ធិតំណាងរបស់ភាគីកម្មករនិយោជិត ដោយលើកឡើងថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន យៃនធើរេន អីភែរីល (ខេមបូឌា) ខូ អិលធីឌី មិនមានសិទ្ធិក្នុង

ការតំណាងឱ្យកម្មករនិយោជិតក្នុងការនាំយកវិវាទការងាររួមមកដោះស្រាយជាមួយនិយោជកនោះទេ ដោយហេតុថា សហជីពនេះ មិនបានបំពេញលក្ខខណ្ឌស្របតាមមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព។ ហេតុនេះ មុននឹងពិចារណាលើការទាមទារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាអំពីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ជេវើលីន ខូអិលធីឌី)*

ទោះជាយ៉ាងណា នៅក្នុងសំណុំរឿងនេះ មិនមានអង្គហេតុ ឬភស្តុតាងណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុនយែនធីរេន មានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង បានបកស្រាយថា ៖ *"...អវត្តមាននៃសហជីពដែលមានភាពជាតំណាងបំផុតនេះ អាចបណ្តាលឱ្យមានភាពរាំងស្ទះដល់សិទ្ធិតំណាងសម្រាប់កម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម និងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមូលដ្ឋានក្នុងការប្តឹងតវ៉ា ឬទាមទារសំណង ដែលផ្តល់ឱ្យកម្មករនិយោជិតដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។*

*...ក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានមួយមិនទាន់មានអត្ថិភាពនៃសហជីពដែលមានភាពជាតំណាងបំផុត កម្មករនិយោជិតដែលជាប់ពាក់ព័ន្ធក្នុងវិវាទមានសិទ្ធិតំណាងដោយផ្ទាល់ខ្លួន ឬមានសិទ្ធិក្នុងការពឹងពាក់ ឬផ្ទេរសិទ្ធិជូនសហជីពមូលដ្ឋាន ឬបុគ្គលផ្សេងទៀត ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រសិនបើពួកគាត់យល់ថា សិទ្ធិរបស់ពួកគាត់ត្រូវបានបំពានដោយនិយោជក។"* ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៧១/១៦-ជេវើលីន ខូអិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

យ៉ាងណាមិញ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

- *ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម ។"* ។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៣/១៦-យូនីកតា ថេកណេឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៦/១៨ កប/អក/វក/លបវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣នាក់ គឺ ១. ឃួន សុខា ២. ចាប ដា និង ៣. អ៊ិន ស្រី ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យៃនធើរេន អ៊ីភែរីល (ខេមបូឌា) ដើម្បីដោះស្រាយវិវាទការងាររួមនៃសំណុំរឿងនេះ ។

នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល កម្មករនិយោជិតដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ២ នាក់ មានវត្តមាន គឺកម្មករនិយោជិត ឃួន សុខា និង ចាប ដា។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ២ នាក់ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន យៃនធើរេន ក្នុងការដោះស្រាយវិវាទការងាររួមនៅក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាចំណុចវិវាទនេះ សម្រាប់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន យៃនធើរេន ដែលជាដើមបណ្តឹង ។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិតរៀងរាល់មួយសប្តាហ៍ម្តង គឺនៅថ្ងៃសៅរ៍នៃសប្តាហ៍នីមួយៗ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិតរៀងរាល់មួយសប្តាហ៍ម្តង គឺនៅថ្ងៃសៅរ៍នៃសប្តាហ៍នីមួយៗ ដែរ ឬទេ?

ARBITRATION COUNCIL

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ចែងថា ៖*"កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយ ចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។"* ។

តាមខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូនដំណឹង ០៤១/១១ ខាងលើនេះ កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់បាយមួយពេលដោយឥតគិតថ្លៃ។ ទោះជាយ៉ាងនេះក៏ដោយ សេចក្តីជូនដំណឹងនេះមិនបានបញ្ជាក់អំពីពេលវេលានៃការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនោះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផ្តល់បាយមួយពេលនេះ គឺជាការផ្តល់កម្លាំងបន្ថែមទៀត ដើម្បីឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងតទៅមុខទៀត ព្រោះថា បាយគឺជាតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់មនុស្សគ្រប់រូបដែលមិនអាចអត់បាន ហើយដែលនិយោជកត្រូវតែផ្តល់ឱ្យ ។ ប្រសិនបើនិយោជកមិនអាចផ្តល់បាយឱ្យកម្មករនិយោជិតនៅពេលធ្វើការបន្ថែមម៉ោង នោះនិយោជកត្រូវផ្តល់ប្រាក់ថ្លៃបាយ ២០០០ រៀល ក្នុងមួយថ្ងៃ ជំនួសការផ្តល់បាយដោយឥតគិតថ្លៃដែរ ។ ដូចនេះ ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដល់កម្មករនិយោជិត ត្រូវធ្វើឡើងក្នុងរយៈពេលមួយសមស្របដែលធានាថា កម្មករនិយោជិតអាចមានប្រាក់ទិញបាយសម្រាប់ហូបពេលធ្វើការបន្ថែមម៉ោង មិនថា ការបើកប្រាក់នេះត្រូវធ្វើឡើងជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្តាហ៍ ឬជារៀងរាល់ខែនោះទេ ឱ្យតែកម្មករនិយោជិតអាចចាត់ចែងប្រាក់នេះសម្រាប់ទិញបាយហូបពេលធ្វើការបន្ថែមម៉ោងបាន ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗយល់ឃើញថា ការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃគឺត្រូវតែធ្វើឡើងជារៀងរាល់ថ្ងៃធ្វើការបន្ថែមម៉ោង ។ ដូច្នេះ វាមានលក្ខណៈសមហេតុផល ដែលប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ត្រូវបើកជូនកម្មករនិយោជិតរៀងរាល់ថ្ងៃដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ការទាមទារបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង គឺអាស្រ័យទៅលើភាពចាំបាច់របស់កម្មករនិយោជិត ។ ជាក់ស្តែង ពេលខ្លះ ទោះបីជាកម្មករនិយោជិតបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងមិនបានរាល់ថ្ងៃក៏ដោយ ក៏គាត់អាចចាត់ចែងក្នុងវិធីណាមួយ ដែលអាចឱ្យគាត់អាចទិញបាយហូបបានរាល់ពេលធ្វើការបន្ថែមម៉ោងដែរ ។ ជួនកាល គាត់អាចចាត់ចែងប្រាក់របស់គាត់ដែលបើករាល់មួយសប្តាហ៍ម្តង ឬរាល់ពីរសប្តាហ៍ម្តង ឬរាល់មួយខែម្តង សម្រាប់យកទៅទិញបាយហូបរាល់ពេលធ្វើការបន្ថែមម៉ោងបាន ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងសម្រេចលើការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនេះ អាស្រ័យលើការចាំបាច់របស់កម្មករនិយោជិត ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៤៧/០៧-ដុងហ្វៃ ហេតុផលនៃចំណុចវិវាទទី៥ និង លេខ ២៤៤/១២-ខមក្លិត អនទើរ ហេតុផលនៃចំណុចវិវាទទី៣)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

យោងតាមអង្គហេតុនៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយបន្ថែមម៉ោងជូនកម្មករនិយោជិត រៀងរាល់មួយសប្តាហ៍ម្តង ដោយហេតុថា កម្មករនិយោជិតត្រូវការប្រាក់ដើម្បីទិញ

ម្ហូបអាហារ ហើយការដែលនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២ សប្តាហ៍ម្តង បង្កការលំបាកដល់កម្មករនិយោជិត ដោយពួកគាត់ត្រូវខ្ចីប្រាក់គេ ឬត្រូវយកប្រាក់ពីផ្ទះមកចាយសិនទម្រាំដល់ថ្ងៃបើកប្រាក់។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតបានទាមទារចំណុចនេះ ដោយផ្អែកលើភាពចាំបាច់របស់ពួកគាត់។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង នៅរៀងរាល់ថ្ងៃសៅរ៍ ទៅតាមភាពចាំបាច់របស់កម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិត រៀងរាល់មួយសប្តាហ៍ម្តង គឺនៅថ្ងៃសៅរ៍ នៃសប្តាហ៍នីមួយៗ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទទី ៤៖

- បង្គាប់ឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត រៀងរាល់មួយសប្តាហ៍ម្តង គឺនៅថ្ងៃសៅរ៍នៃសប្តាហ៍នីមួយៗ។

ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖

ឈ្មោះ៖ **យុ សូនធី**

ហត្ថលេខា៖ ---------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖

ឈ្មោះ៖ **ស៊ុន គឹមស៊ាន**

ហត្ថលេខា៖---------------------------

ប្រធានក្រុមអាជ្ញាកណ្តាល៖

ឈ្មោះ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា៖ ---------------------------

THE ARBITRATION COUNCIL